*Actus Legis Nemini Est Damnosus*
An Act in Law Shall Prejudice No Man
អំពីចែងក្នុងច្បាប់ មិនត្រូវប៉ះពាល់ដល់មនុស្ស
(A Selection of Legal Maxims, 1874, pp. 125-126)

ទោះបីជា គោលការណ៍ទូទៅចែងថា ប្រសិនបើបុរសម្នាក់រៀបការជាមួយកូនបំណុល (ស្ត្រី)របស់គាត់ នោះបំណុលនឹងត្រូវបានជម្រះ ក៏ប៉ុន្តែវាអាចនៅមានករណី តាមកាលៈទេសៈ តម្រូវឲ្យមិនគោរពតាមគោលការណ៍នេះ។ ឧទាហរណ៍ មូលប័ត្របំណុល (bond) ជាលក្ខខណ្ឌសម្រាប់ទូទាត់លុយក្រោយពីការស្លាប់របស់ម្ចាស់បំណុល (obligor) ផ្តល់ជូនស្ត្រីសម្រាប់ការពិចារណាលើការរៀបការរបស់ម្ចាស់បំណុលជាមួយនាងនិងដើម្បីផលប្រយោជន៍នាង ដែលនាងអាចរស់រានបាន មូលប័ត្របំណុលមិនអាចត្រូវបានជម្រះដោយសារការរៀបការទេ។ ក៏ប៉ុន្តែ នាងអាចដាក់ពាក្យបណ្តឹងទាមទារ (lie at suit) ប្រឆាំងនឹងអ្នកទទួលមរតក (executor)។ ការអះអាងនេះ ទាញចេញពីគោលការណ៍ថា ច្បាប់នឹងមិនត្រូវបានអនុវត្តឲ្យខុសទេ ចំពោះមូលប័ត្របំណុលផ្តល់សម្រាប់ប្រពន្ធ ក្នុងករណីនាងអាចរស់រានដោយខ្លួនឯង ហើយវាអាចអយុត្តិធម៌ក្នុងការបដិសេធសងបំណុល ផ្អែកលើអាពាហ៍ពិពាហ៍ ដោយសារ មូលប័ត្របំណុលតម្រូវឲ្យមានការសងត្រឡប់វិញ។

អាស្រ័យហេតុនេះ នៅពេលដែលអំណាចផ្តល់ដោយច្បាប់ ត្រូវបានអនុវត្តដោយបំពាន ច្បាប់ដាក់ភាគីដែលបំពាន ក្នុងស្ថានភាពដូចគ្នា ដូចជាគាត់បានធ្វើតាំងពីដំបូងដោយគ្មានអំណាច។ ដូចដែលបានកត់សំគាល់ គោលការណ៍នេះ គ្រាន់តែជាគោលការណ៍យុត្តិធម៌ ផ្អែកតាមទ្រឹស្តី ថាច្បាប់មិនត្រូវបានអនុវត្តខុសលើមនុស្ស។